# សេចក្តីបន្ថែមទៅលើពិធីការសម្រាប់ផែនការគ្រប់គ្រងការប៉ះពាល់នឹងជំងឺ COVID-19 នៅសាលារៀន K-12៖ ការគ្រប់គ្រងការផ្ទុះជំងឺ COVID-19៖

**បច្ចុប្បន្នភាពថ្មីៗ** - ការផ្លាស់ប្តូរត្រូវបានរំលេចដោយពណ៌លឿងនៅក្នុងឯកសារទាំងមូល។

**1/25/21៖** បានធ្វើបច្ចុប្បន្នភាពដើម្បីបញ្ជាក់ថា គេត្រូវតែរក្សាការសម្ងាត់នៅពេលចេញការជូនដំណឹងអំពីការប៉ះពាល់ដែលអាចមាន ដើម្បីឆ្លុះបញ្ចាំងពីលក្ខខ័ណ្ឌតម្រូវដែលបានកែសម្រួលសម្រាប់ការប្រើប្រាស់របាំងមុខ និងសន្ទះបាំងមុខ ដើម្បីបញ្ជាក់ព័ត៌មានលម្អិតពាក់ព័ន្ធនឹងការត្រួតពិនិត្យការចូល ដើម្បីធ្វើបច្ចុប្បន្នភាពលក្ខខ័ណ្ឌតម្រូវសម្រាប់ការជូនដំណឹង និងការមិនរាប់បញ្ចូល និងដើម្បីតម្រូវឲ្យមានការបិទជាបណ្តោះអាសន្ននូវសាលារៀន K-12 ដែលកំពុងមានការផ្ទុះជំងឺ COVID-19។ បន្ថែមលើនេះ តំណភ្ជាប់ទៅកាន់ COVID-19 Toolkit នៃសាលារៀន K-12 ក៏ត្រូវបានបន្ថែមផងដែរ។

ការឆ្លើយតបសុខភាពសាធារណៈមានគោលដៅដើម្បីគ្រប់គ្រងការប៉ះពាល់នៃជំងឺ COVID-19 នៅកម្រិតសហគមន៍ អាចជួយបង្កើនឥទ្ធិពលជារួមនៃការឆ្លើយតបនឹងជំងឺ COVID-19 របស់នាយកដ្ឋានសុខភាពសាធារណៈរបស់ខោនធី Los Angeles (DPH)។

សាលាបឋមសិក្សា និងមធ្យមសិក្សាដែលបម្រើសិស្សពីថ្នាក់មត្តេយ្យដល់ថ្នាក់ទី 12 (សាលារៀន K-12) គឺជាដៃគូសហគមន៍ដែលបានទុកចិត្ត។ សាលារៀន K-12 ដែលកំពុងជួបប្រទះការផ្ទុះជំងឺ COVID-19 អាចជួយ DPH កែលម្អភាពទាន់ពេលវេលា និងផលប៉ះពាល់នៃការឆ្លើយតបសុខភាពសាធារណៈដោយអនុវត្តវិធានការណ៍គ្រប់គ្រងការផ្ទុះជំងឺដើម្បីជួយគ្រប់គ្រងការផ្ទុះជំងឺ និងទប់ស្កាត់ការរីករាលដាលបន្ថែមនៃជំងឺ COVID-19។

សកម្មភាពអប់រំដែលផ្តល់ជូនដោយសាលារៀន K-12 ត្រូវតែធ្វើឡើងដោយអនុលោមតាមមាត្រាទាំងអស់សម្រាប់ការបើកសាលារៀនដោយសុវត្ថិភាពដែលបានពិពណ៌នាយ៉ាងលម្អិតនៅក្នុងពិធីការបើកឡើងវិញសម្រាប់សាលារៀន K-12 របស់ DPH។ ផែនការគ្រប់គ្រងការប៉ះពាល់នឹងជំងឺ COVID-19 នៅសាលារៀន K-12 របស់ DPH គូសបញ្ជាក់ពីជំហានដែលបានណែនាំ និងចាំបាច់បន្ថែមដើម្បីគ្រប់គ្រងការប៉ះពាល់សម្រាប់ករណីជំងឺ COVID-19 ចំនួន 1, 2 និង 3 ឬច្រើនជាងនេះនៅសាលារៀន K-12។ លើសពីនេះ បើសិនជាសាលារៀនកំពុងជួបប្រទះការផ្ទុះជំងឺ COVID-19 សាលាត្រូវតែអនុវត្តវិធានការណ៍ដែលបានរៀបរាប់នៅក្នុងសេចក្តីបន្ថែមនេះ។ សេចក្តីបន្ថែមនេះ រាប់បញ្ចូលសកម្មភាពស្នូលដែលត្រូវបានណែនាំដើម្បីទប់ស្កាត់ការរីករាលដាលបន្ថែមនៃជំងឺ COVID-19។ វិធានការណ៍បន្ថែម អាចត្រូវបានណែនាំ ឬចាំបាច់សម្រាប់ទីកន្លែងដែលកំពុងជួបប្រទះការផ្ទុះជំងឺ។

ការផ្ទុះជំងឺត្រូវបានកំណត់និយមន័យថា៖ ករណីដែលបានបញ្ជាក់ពីមន្ទីរពិសោធន៍យ៉ាងតិច 3 ករណីជាមួយជំងឺ COVID-19 ដែលមានរោគសញ្ញា ឬគ្មានរោគសញ្ញាក្នុងរយៈពេល 14 ថ្ងៃនៅក្នុងក្រុមមួយ* ដែលមានសមាជិកទាក់ទងនឹងការរីករាលដាលនៃជំងឺ មិនរស់នៅក្នុងគ្រួសារតែមួយ និងមិនមែនជាអ្នកប៉ះពាល់ជិតស្និទ្ធនឹងគ្នានៅខាងក្រៅបរិវេណសាលា។ *ក្រុមសាលារៀន រាប់បញ្ចូលបុគ្គលដែលមានសមាជិកភាពទូទៅដូចគ្នានៅសាលារៀន (ឧ. បន្ទប់រៀន ព្រឹត្តិការណ៍សាលា សកម្មភាពក្រៅកម្មវិធីសិក្សារបស់សាលា ថ្នាក់សិក្សា ក្រុមកីឡា ក្លិប មធ្យោបាយធ្វើដំណើរ)។ ការទាក់ទងនឹងការរីករាលដាលនៃជំងឺ តម្រូវឲ្យមនុស្សឈឺមានវត្តមាននៅចំណុចណាមួយនៅទីកន្លែងដូចគ្នាក្នុងពេលតែមួយខណៈដែលមនុស្សម្នាក់ឬច្រើននាក់អាចចម្លងជំងឺ។

ឯកសារនេះអាចនឹងត្រូវបានធ្វើបច្ចុប្បន្នភាពនៅពេលដែលមានព័ត៌មាន និងធនធានថ្មីៗ។ សូមចូលទៅកាន់គេហទំព័រជំងឺ COVID-19 របស់នាយកដ្ឋានសុខភាពសាធារណៈ: http://ph.lacounty.gov/media/Coronavirus ជាប្រចាំដើម្បីពិនិត្យមើលបច្ចុប្បន្នភាព និងធនធានបន្ថែម។

## វិធានការណ៍គ្រប់គ្រងការផ្ទុះជំងឺនៅសាលារៀន K-12

បើសិនជាមានការផ្ទុះជំងឺ COVID-19 នៅសាលារៀន K-12 ក្រុមការងារឆ្លើយតបនឹងការផ្ទុះជំងឺរបស់ DPH (Outbreak Field Response Team) នឹងសម្របសម្រួលជាមួយសាលារៀនដើម្បីបង្កើត និងអនុវត្តផែនការឆ្លើយតបនឹងការផ្ទុះជំងឺ។ អ្នកស៊ើបអង្កេតការផ្ទុះជំងឺ (Outbreak Investigator) នឹងត្រូវបានចាត់តាំងជាអ្នក

ទំនាក់ទំនងជាមួយសាលា និងផ្តល់ការណែនាំ ជំនួយបច្ចេកទេស និងធនធានដើម្បីគាំទ្រសាលារៀនក្នុងការអនុវត្តវិធានការណ៍ឆ្លើយតបនឹងការផ្ទុះជំងឺខាងក្រោម និងវិធានការណ៍ផ្សេងទៀតណាមួយ។ វិធានការណ៍ទាំងនេះអាចជួយគ្រប់គ្រងការផ្ទុះជំងឺ និងការពារសិស្ស គ្រូបង្រៀន និងបុគ្គលិកពីជំងឺ COVID-19។

**ការធ្វើផែនការឆ្លើយតបនឹងការផ្ទុះជំងឺ**

☑ *ចាំបាច់៖* សាលារៀនត្រូវតែចាត់តាំងកងកម្លាំងអនុវត្តច្បាប់សម្រាប់ជំងឺ COVID-19 (COVID-19 Compliance Task Force) ដែលទទួលខុសត្រូវលើការបង្កើត និងការអនុវត្តពិធីការសុវត្ថិភាពសម្រាប់ជំងឺ COVID-19 ទាំងអស់ និងធ្វើឲ្យប្រាកដថាបុគ្គលិក និងសិស្សទទួលបានការអប់រំអំពីជំងឺ COVID-19។

☑ *ចាំបាច់៖* សាលារៀនត្រូវតែចាត់តាំង មន្ត្រីអនុវត្តច្បាប់សម្រាប់ជំងឺ COVID-19 ម្នាក់ ដើម្បីដើរតួជាអ្នកទំនាក់ទំនងជាមួយ DPH រហូតដល់សាលារៀនបានទទួលដំណឹងថា ការផ្ទុះជំងឺបានបញ្ចប់។

**ការបិទទីកន្លែងជាបណ្តោះអាសន្នសម្រាប់សាធារណជន**

☑ *ចាំបាច់៖* បើសិនជាមានការផ្ទុះជំងឺនៅទីកន្លែង គេត្រូវតែបញ្ឈប់ប្រតិបត្តិការដោយផ្ទាល់ទាំងអស់នៅទីកន្លែងនោះនៅចុងបញ្ចប់នៃថ្ងៃធ្វើការ លើកលែងតែប្រតិបត្តិការមូលដ្ឋានអប្បបរមា ហើយទីកន្លែងត្រូវតែបិទទ្វារដល់សាធារណជនរយៈពេល 14 ថ្ងៃគិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើមនៃការផ្ទុះជំងឺនៅទី កន្លែងដូចបានកំណត់ដោយ Public Health។ ក្នុងអំឡុងពេលនោះ សិស្ស គ្រូបង្រៀន បុគ្គលិក ឬសាធារណជនមិនអាចមានវត្តមានដោយផ្ទាល់នៅទីកន្លែងបានឡើយ លើកលែងតែបុគ្គលិក ឬបុគ្គល ផ្សេងទៀតដែលត្រូវបានតម្រូវឲ្យមានវត្តមាននៅទីនោះដើម្បីធ្វើការសម្អាត និងសម្លាប់មេរោគដែលចាំ បាច់នៅទីកន្លែង និងដើម្បីរក្សាប្រតិបត្តិការមូលដ្ឋានអប្បបរមា ដែលជាសកម្មភាពមូលដ្ឋានចាំបាច់ដើម្បី៖

- រក្សា និងការពារតម្លៃនៃសារពើភ័ណ្ឌ និងបរិក្ខារនៃសាលារៀន
- ធានាបាននូវសុវត្ថិភាព សន្តិសុខ និងអនាម័យ
- ដំណើរការការបើកប្រាក់ខែ អត្ថប្រយោជន៍បុគ្គលិក និងសកម្មភាពគ្រប់គ្រងដែលពាក់ព័ន្ធ
- ធានាថាបុគ្គលិកអាចធ្វើការពីចម្ងាយ និងថាសាលារៀនអាចផ្តល់សេវាកម្មអប់រំដល់សិស្សតាមរយៈការសិក្សាពីចម្ងាយ
- រៀបចំនិងចែកម្ហូបអាហារឥតគិតថ្លៃ និងមានតម្លៃទាបដល់សិស្សដែលមានសិទ្ធិទទួល សម្រាប់ការមកយកតែប៉ុណ្ណោះ
- ជួយដល់តំណាង public Health ក្នុងការស៊ើបអង្កេតពីការផ្ទុះជំងឺ
- អនុវត្តការកែប្រែនៃការគ្រប់គ្រងការឆ្លងជំងឺដែលចាំបាច់

សាលារៀនត្រូវតែរំសាយថ្នាក់រៀន និងសកម្មភាពសាលារៀនទាំងអស់ដែលតម្រូវឲ្យមានវត្តមានផ្ទាល់របស់សិស្ស គ្រូបង្រៀន បុគ្គលិក និង/ឬសាធារណជននៅទីកន្លែង រយៈពេល 14 ថ្ងៃគិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើមនៃការផ្ទុះជំងឺនៅទីកន្លែង ដូចបានកំណត់ដោយ Public Health។ ថ្នាក់រៀន និងសកម្មភាពសាលារៀនរាប់បញ្ចូល តែមិនដាក់កម្រិតត្រឹមសកម្មភាពសិក្សា ក្រៅកម្មវិធីសិក្សា អត្តពលកម្ម (រួមមានកីឡាយុវជន) ការថែទាំពេលថ្ងៃសម្រាប់កុមារគ្រប់អាយុចូលរៀន ការបោះឆ្នោត និងសកម្មភាពសហគមន៍ដែលប្រព្រឹត្តទៅមុនពេល អំឡុងពេល និងបន្ទាប់ពីម៉ោងសិក្សាស្ថិតនៅ ឬក្រៅពីបរិវេណសាលារៀន។ សាលារៀនអាចបន្តធ្វើប្រតិបត្តិការមូលដ្ឋានអប្បបរមា និងសកម្មភាពប្រើប្រាស់ពីចម្ងាយ ដែលរួមមានថ្នាក់រៀនតាមអនឡាញ វេបិណា សន្និសីទពីចម្ងាយ និងសន្និសីទជាវីដេអូដែលមិនតម្រូវឲ្យសិស្សមានវត្តមានផ្ទាល់នៅទីកន្លែង ឬបរិបទជាក្រុមផ្សេងៗទៀត។

**ការកំណត់អត្តសញ្ញាណករណីជំងឺ COVID-19 និងអ្នកប៉ះពាល់ជិតស្និទ្ធ**

☑ *ចាំបាច់៖* សាលារៀនត្រូវតែដាក់ស្នើជូនទៅអ្នកស៊ើបអង្កេតការផ្ទុះជំងឺរបស់ DPH ដែលត្រូវបានចាត់តាំងសម្រាប់សាលានូវតារាងសង្ខេបព័ត៌មានទំនាក់ទំនង (Line Lists) ដូចខាងក្រោមក្នុងរយៈពេល 24 ម៉ោង និងដាក់ស្នើបច្ចុប្បន្នភាពតាមការណែនាំ៖

- តារាងសង្ខេបព័ត៌មានទំនាក់ទំនងករណី ដែលផ្ដល់ព័ត៌មានអំពីបុគ្គលទាំងអស់ដែលត្រូវបានកំណត់អត្តសញ្ញាណថាជាករណីជំងឺ COVID-19 (ដូចបានកំណត់និយមន័យដោយ DPH) នៅទីកន្លែងសាលារៀន។ កំណត់សម្គាល់៖ តារាងសង្ខេបព័ត៌មានទំនាក់ទំនងត្រូវតែរាប់បញ្ចូលករណីជំងឺ COVID-19 ក្នុងចំណោមបុគ្គលិក និងកុមារដែលធ្លាប់មានវត្តមាននៅទីធ្លាសាលារៀននៅចំណុចណាមួយក្នុងរយៈពេល 14 ថ្ងៃមុនពេលធ្លាក់ខ្លួនឈឺ។
- តារាងសង្ខេបព័ត៌មានទំនាក់ទំនងដែលបានប៉ះពាល់ជាសក្ដានុពល ដែលផ្ដល់ព័ត៌មានអំពីបុគ្គលទាំងអស់ដែលអាចត្រូវបានប៉ះពាល់ជាសក្ដានុពលជាមួយករណីជំងឺ COVID-19 (អ្នកប៉ះពាល់ជិតស្និទ្ធ ដូចបានកំណត់និយមន័យដោយ DPH) នៅទីកន្លែងសាលារៀន។

បើសិនជាមិនអាចដាក់ស្នើតារាងសង្ខេបព័ត៌មានទំនាក់ទំនងតាមពេលវេលាដែលបានបញ្ជាក់ សាលារៀនត្រូវតែទាក់ទងជាមួយអ្នកស៊ើបអង្កេតការផ្ទុះជំងឺរបស់ DPH ភ្លាមៗទាក់ទងនឹងផែនការសម្រាប់ការដាក់ស្នើរហ័ស។ សាលារៀនត្រូវតែដាក់ស្នើព័ត៌មាននេះតាមរយៈ [តារាងសង្ខេបព័ត៌មានទំនាក់ទំនងករណីជំងឺ COVID-19 និងអ្នកប៉ះពាល់សម្រាប់វិស័យអប់រំ]។ ករណីលើកលែងមួយដើម្បីប្រើតារាងសង្ខេបព័ត៌មានទំនាក់ទំនងដែលមានទ្រង់ទ្រាយក្នុងតំបន់ អាចត្រូវបានអនុញ្ញាត បើសិនជាធាតុនៃទិន្នន័យដែលចាំបាច់ទាំងអស់ ត្រូវបានរាប់បញ្ចូល និងបានអនុម័តសម្រាប់ការប្រើប្រាស់ដោយក្រុមការងារឆ្លើយតបនឹងការផ្ទុះជំងឺរបស់ DPH។

## ការជូនដំណឹង និងការមិនរាប់បញ្ចូល

☑ *ចាំបាច់៖* សាលារៀនត្រូវតែណែនាំករណីជំងឺ COVID-19 ថាពួកគេត្រូវតែអនុវត្តតាម [សេចក្ដីបង្គាប់ឲ្យដាក់ខ្លួននៅដាច់ដោយឡែកជាបន្ទាន់ (Emergency Isolation Order)] និង [ការណែនាំអំពីការដាក់ឲ្យនៅដាច់ដោយឡែកនៅផ្ទះសម្រាប់ជំងឺ COVID-19 (Home Isolation Instructions for COVID-19)] របស់នាយកដ្ឋានសុខភាពសាធារណៈខោនធី Los Angeles។

☑ *ចាំបាច់៖* សាលារៀនត្រូវតែជូនដំណឹងដល់បុគ្គលទាំងអស់ ដែលត្រូវបានកំណត់អត្តសញ្ញាណថាជាអ្នកប៉ះពាល់ជិតស្និទ្ធជាមួយករណីជំងឺ COVID-19 អំពីការប៉ះពាល់ដែលអាចមានរបស់ពួកគេជាមួយជំងឺ COVID-19 នៅទីកន្លែងសាលារៀន និងណែនាំឲ្យពួកគេអនុវត្តតាម [សេចក្ដីបង្គាប់ឲ្យនៅដាច់ពីគេជាបន្ទាន់ (Emergency Quarantine Order)] និង [ការណែនាំអំពីការនៅដាច់ពីគេនៅផ្ទះសម្រាប់ជំងឺ COVID-19 (Home Quarantine Instructions for COVID-19)] របស់នាយកដ្ឋានសុខភាពសាធារណៈខោនធី Los Angeles។ នៅពេលជូនដំណឹងបុគ្គលដែលបានប៉ះពាល់ គេត្រូវអនុវត្តការប្រុងប្រយ័ត្នសមស្របដើម្បីរក្សាការសម្ងាត់របស់ករណី។

គំរូលិខិតជូនដំណឹងអំពីការប៉ះពាល់របស់សាលាគឺមាននៅ៖ [គំរូលិខិតជូនដំណឹងអំពីជំងឺ COVID-19 សម្រាប់ទីកន្លែងអប់រំ (COVID -19 Template Notification Letters for Education Settings)]។ ការជូនដំណឹងអំពីការប៉ះពាល់គួររាប់បញ្ចូលសារដូចខាងក្រោម៖

- សិស្ស និងបុគ្គលិកដែលមានការប៉ះពាល់ជាមួយករណី គួរធ្វើតេស្តរកជំងឺ COVID-19 មិនថាពួកគេមានរោគសញ្ញាឬក៏អត់នោះទេ ហើយជូនដំណឹងដល់សាលាអំពីលទ្ធផលតេស្ត។ លទ្ធផលពីការធ្វើតេស្តនឹងកំណត់ពីកម្រិតរីករាលដាលនៃជំងឺនៅសាលារៀន និងដើរតួជាមូលដ្ឋានសម្រាប់វិធានការណ៍គ្រប់គ្រងបន្ថែម។ ធនធានធ្វើតេស្តរួមមាន៖ សេវាកម្មសុខភាពបុគ្គលិក ឬសេវាកម្មសុខភាពការងារ មណ្ឌលសុខភាពសិស្ស អ្នកផ្ដល់សេវាថែទាំសុខភាពផ្ទាល់ខ្លួន និងទីកន្លែងធ្វើតេស្តសហគមន៍៖[covid19.lacounty.gov/testing]។ បុគ្គលដែលត្រូវការជំនួយក្នុងការស្វែងរកសេវាថែទាំសុខភាព អាចទូរសព្ទទៅខ្សែទូរសព្ទព័ត៌មានរបស់ខោនធី Los Angeles តាមរយៈលេខ 2-1-1 ដែលអាចទាក់ទងបាន 24/7។
- សិស្ស និងបុគ្គលិកដែលបានប៉ះពាល់ គួរនៅដាច់ពីគេរយៈពេល 10 ថ្ងៃចាប់ពីការប៉ះពាល់ចុងក្រោយជាមួយករណីខណៈពេលអាចចម្លងមេរោគ ទោះបីជាពួកគេទទួលបានលទ្ធផលតេស្តអវិជ្ជមានក្នុងអំឡុងរយៈពេលនៅដាច់ពីគេរបស់ពួកគេក៏ដោយ។ បើសិនជាពួកគេនៅតែមិនចេញរោគសញ្ញា ពួកគេត្រូវបានដោះលែងពីការនៅដាច់ពីគេបន្ទាប់ពីថ្ងៃទី 10 ប៉ុន្តែត្រូវតែបន្តតាមដានសុខភាពរបស់ពួកគេ និងគោរពតាមការប្រុងប្រយ័ត្នដើម្បីបង្ការជំងឺ COVID-19 ឲ្យបានតឹងរ៉ឹងរហូតដល់ថ្ងៃទី 14។ កំណត់សម្គាល់៖ បុគ្គលដែលធ្វើតេស្ត អវិជ្ជមានអាចនឹងកើតជំងឺនៅពេលក្រោយ ដោយមានឬគ្មានរោគសញ្ញា បើសិនជាបានធ្វើតេស្តក្នុងអំឡុងរយៈពេលសម្ងំ (ឧ. រយៈពេលចន្លោះពីការប៉ះពាល់ដល់ការចាប់ផ្ដើមកើតជាជំងឺ)។ មើល [ការណែនាំអំពីការនៅដាច់ពីគេនៅផ្ទះសម្រាប់ជំងឺ COVID-19]។
- DPH ក៏នឹងទាក់ទងទៅករណី ក៏ដូចជាសិស្ស និងបុគ្គលិកដែលបានប៉ះពាល់ដោយផ្ទាល់តាមរយៈកម្មវិធីស៊ើបអង្កេតករណី និងការប៉ះពាល់របស់ DPH ដើម្បីប្រមូលព័ត៌មានបន្ថែម និងចេញ សេចក្ដីបង្គាប់

ឲ្យដាក់ខ្លួននៅដាច់ដោយឡែកជាបន្ទាន់ ឬ សេចក្តីបង្គាប់ឲ្យនៅដាច់ពីគេជាបន្ទាន់ របស់នាយកដ្ឋានសុខភាពសាធារណៈ ខោនធី Los Angeles តាមការគួរផងដែរ។

☑ *ចាំបាច់៖* សាលារៀននឹងកំណត់ថាតើចាំបាច់ត្រូវធ្វើការជូនដំណឹងបន្ថែមដល់សហគមន៍សាលារៀនដ៏ទូលំទូលាយជាងមុនអំពីការប៉ះពាល់នៅសាលារៀន និងការប្រុងប្រយ័ត្នដែលកំពុងត្រូវបានអនុវត្តដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺ COVID-19 ឬក៏អត់។ គំរូលិខិតជូនដំណឹងទូទៅគឺមាននៅ គំរូលិខិតជូនដំណឹងអំពីជំងឺ COVID-19 សម្រាប់ទីកន្លែងអប់រំ។ បើសិនជាមិនស្គាល់អត្តសញ្ញាណរបស់អ្នកប៉ះពាល់ជិតស្និទ្ធ ឬមិនអាចទាក់ទងបាន សាលារៀនត្រូវតែធ្វើការជាមួយ DPH ដើម្បីបង្កើតនិងចេញសេចក្តីជូនដំណឹងជាសាធារណៈ។ ចំនួន និងទីតាំងនៃការផ្ទុះជំងឺ ក៏នឹងត្រូវបានចុះផ្សាយជាសាធារណៈដោយមិនមានគ្រឿងសម្គាល់ផ្ទាល់ខ្លួននៅលើ គេហទំព័រ DPH ផងដែរ រហូតដល់ការផ្ទុះជំងឺត្រូវបានដោះស្រាយ។

☑ *ចាំបាច់៖* សាលារៀនត្រូវតែដកករណី និងអ្នកប៉ះពាល់ជិតស្និទ្ធជាមួយករណីចេញពីការធ្វើការ ការទទួលសេវា ឬការចូលរួមក្នុងសកម្មភាពទាំងឡាយនៅទីកន្លែងសាលារៀន រហូតដល់ពួកគេបំពេញតាមលក្ខណៈវិនិច្ឆ័យដើម្បីដោះលែងពី ការដាក់ខ្លួនឲ្យនៅដាច់ដោយឡែក ឬ ការដាក់ខ្លួនឲ្យនៅដាច់ពីគេ។

☑ *ចាំបាច់៖* សាលារៀនត្រូវតែធ្វើការជាមួយ DPH ដើម្បីបង្កើតផែនការដើម្បីសម្របសម្រួលដល់ការធ្វើតេស្តរោគវិនិច្ឆ័យសម្រាប់បុគ្គលដែលបានប៉ះពាល់នៅទីកន្លែងសាលារៀន និងផ្តល់ការណែនាំបន្តដល់ធនធានដែលមានសម្រាប់ការធ្វើតេស្ត (ឧ. តាមដែលអាចអនុវត្តបាន សេវាសុខភាពបុគ្គលិក/សុខភាពការងារ សេវាសុខភាពសិស្ស អ្នកផ្តល់សេវាថែទាំសុខភាពផ្ទាល់ខ្លួន សេវាធ្វើតេស្តពាណិជ្ជកម្ម និង/ឬទីកន្លែងធ្វើតេស្តក្នុងសហគមន៍៖ covid19.lacounty.gov/testing)។

☑ *ចាំបាច់៖* សាលារៀនត្រូវតែរាយការណ៍ពីករណីជំងឺ COVID-19 បន្ថែមណាមួយ ក៏ដូចជាការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងការស្លាប់ដែលកើតឡើងក្នុងចំណោមករណី និងអ្នកប៉ះពាល់ទៅកាន់អ្នកស៊ើបអង្កេតការផ្ទុះជំងឺរបស់ DPH ដែលត្រូវបានចាត់តាំងឲ្យសាលារៀន។

## វិធានការណ៍គ្រប់គ្រងការផ្ទុះជំងឺបន្ថែម

☑ *ចាំបាច់៖* សលារៀន ត្រូវតែអនុវត្តតាមការណែនាំអំពីការសម្អាត និងការសម្លាប់មេរោគរបស់នាយកដ្ឋានសុខភាពសាធារណៈ ដែលរួមមានការផ្តល់ការសម្អាត និងការសម្លាប់មេរោគទៅលើគ្រឿងបរិក្ខារ បរិស្ថានអប់រំ/ការងារ ផ្ទៃ និងវត្ថុដែលបានប៉ះពាល់ញឹកញាប់បន្ទាប់ពីមានការប៉ះពាល់នឹងជំងឺ COVID-19 ដែលអាចកើតឡើង និងការបង្កើនការសម្អាត និងការសម្លាប់មេរោគជាទម្លាប់ ដោយប្រើផលិតផលសម្អាតដែលបានអនុម័ត និងមាននៅក្នុង បញ្ជី "N" ដែលបានអនុម័តដោយភ្នាក់ងារការពារបរិស្ថាន (EPA) តាមការណែនាំរបស់ផលិតផល។ នៅពេលដែលមិនមានសារធាតុសម្លាប់មេរោគដែលបានអនុម័តដោយ EPA សារធាតុសម្លាប់មេរោគជម្រើសផ្សេងទៀតអាចត្រូវបានប្រើប្រាស់ (ឧទាហរណ៍ 1/3 ពែងនៃ bleach ដាក់ទៅក្នុងទឹក 1 ហ្គាឡុង ឬសូលុយស្យុងអាល់កុល 70%)។ កុំលាយ bleach ឬផលិតផលសម្អាត និងសម្លាប់មេរោគផ្សេងទៀតចូលគ្នា - វាអាចបណ្តាលឲ្យមានផ្សែងពុលដែលមានគ្រោះថ្នាក់ខ្លាំងណាស់ក្នុងការដកដង្ហើម។

☑ *ចាំបាច់៖* សាលារៀនត្រូវតែផ្តល់ឲ្យបុគ្គលិកទាំងអស់ដែលមានការប៉ះពាល់ជាមួយសិស្ស អតិថិជន សាធារណជន ឬបុគ្គលិកផ្សេងទៀតនៅទីកន្លែងសាលារៀននូវក្រណាត់បាំងមុខដើម្បីពាក់នៅទីកន្លែងដោយឥតគិតថ្លៃ លុះត្រាតែមិនត្រូវបានណែនាំដោយសារអាយុ ឬបញ្ហាការយល់ដឹង ឬបញ្ហាសុខភាពប្រចាំកាយ។ សាលារៀនក៏ត្រូវតែផ្តល់សន្ទះបាំងមុខដើម្បីពាក់បន្ថែមលើក្រណាត់បាំងមុខដល់បុគ្គលិកទាំងឡាយណាដែលថែទាំកុមារឈឺ ឬអ្នកដែលប៉ះ ពាល់ជាមួយកុមារនានាដែលមានបញ្ហាសុខភាពដែលរារាំងកុមារពីការប្រើប្រាស់ក្រណាត់បាំងមុខផងដែរ។

☑ *ចាំបាច់៖* សាលារៀនត្រូវតែអនុវត្តតាមការណែនាំអំពីការគ្រប់គ្រងប្រភពដែលបានរៀបរាប់នៅក្នុង ការណែនាំសម្រាប់របាំងមុខ (Guidance for Face Coverings) និង ពិធីការបើកឡើងវិញសម្រាប់សាលារៀន K-12។ ដើម្បីដោះស្រាយការចម្លងជំងឺដែលគ្មានរោគសញ្ញា និងមុនពេលចេញរោគសញ្ញា សាលារៀនត្រូវតែតម្រូវឲ្យបុគ្គលទាំងអស់ដែលចូលមក និងស្ថិតនៅក្នុងទីកន្លែងដោយរាប់បញ្ចូលទាំងកុមារអាយុ 2 ឆ្នាំឡើងទៅ ពាក់ក្រណាត់បាំងមុខគ្របលើច្រមុះ និងមាត់របស់ពួកគេនៅពេលចូលមក និងនៅពេលស្ថិតនៅក្នុងទីកន្លែងរួម ផ្លូវដើរ ឬទីកន្លែងដែលមនុស្សអាចនឹងប្រមូលផ្តុំ លុះត្រាតែមិនត្រូវបានណែនាំដោយសារអាយុ ឬបញ្ហាការយល់ដឹង ឬបញ្ហាសុខភាព ប្រចាំកាយ។ បុគ្គលិកត្រូវតែពាក់របាំងមុខនៅគ្រប់ពេលវេលា លើកលែងតែពេលធ្វើការម្នាក់ឯងនៅក្នុងការិយាល័យឯកជនដោយបិទទ្វារជិត ឬនៅពេលបរិភោគ ឬផឹក។ បុគ្គលណាម្នាក់ដែលត្រូវបានលើកលែងពីការពាក់របាំង មុខដោយសារល័ក្ខខ័ណ្ឌការយល់ដឹង ឬវេជ្ជសាស្ត្រ ត្រូវតែពាក់ជម្រើសផ្សេងដូចជាសន្ទះបាំងមុខដែលមានក្រណាត់គ្របនៅគែមខាងក្រោម (យកល្អគួរប្រើក្រណាត់គ្របដែលមានទម្រង់រឹតតឹងនៅខាងក្រោមចង្កា) ដរាបណាល័ក្ខខ័ណ្ឌសុខភាពរបស់ពួកគេអនុញ្ញាត។ កុមារដែលមានអាយុ 2 ឆ្នាំដល់ 8 ឆ្នាំគួរប្រើរបាំងមុខដោយមានការគ្រប់ គ្រង

ដោយមនុស្សធំ ដើម្បីប្រាកដថាកុមារអាចដកដង្ហើមដោយសុវត្ថិភាព និងចៀសវាងការស្ទះខ្យល់ ឬដកដង្ហើមមិនរួច។

☑ *ចាំបាច់៖* សាលារៀន ត្រូវតែអនុវត្តវិធានការណ៍រក្សាគំលាតសង្គម (រាងកាយ) ទាំងអស់នៅក្នុង ពិធីការស្តីពីការរក្សាគំលាតសង្គម និង ពិធីការបើកឡើងវិញសម្រាប់សាលារៀន K-12របស់ខោនធី Los Angeles បច្ចុប្បន្ន។ វារួមមានការគោរពតាមការរក្សាគំលាតសង្គម (រាងកាយ) ដែលបានតម្រូវនៅក្នុងករណីដែលការពាក់ក្រណាត់បាំងមុខគឺមិនចាំបាច់ (ឧ. នៅពេលបរិភោគ ឬផឹក)។

☑ *ចាំបាច់៖* សាលារៀនត្រូវតែធ្វើការត្រួតពិនិត្យការចូលតាម ការណែនាំអំពីការត្រួតពិនិត្យការចូល (Entry Screening Guide) របស់ DPH និងពិធីការបើកឡើងវិញសម្រាប់សាលារៀន K-12។ ការត្រួតពិនិត្យត្រូវតែរាប់បញ្ចូលសំណួរពាក់ព័ន្ធនឹង រោគសញ្ញាដែលដូចគ្នាជាមួយជំងឺ COVID-19 ដែលអាចមាន រោគសញ្ញាផ្សេងទៀតដែលបុគ្គលអាចនឹងកំពុងមាន និងថាតើបុគ្គលនោះបានប៉ះពាល់ជាមួយករណីជំងឺ COVID-19 ក្នុងរយៈពេល 14 ថ្ងៃចុងក្រោយនេះឬក៏អត់។ ការពិនិត្យសីតុណ្ហភាពក៏គួរតែធ្វើឡើងមុនពេលចូលក្នុងទីកន្លែងផងដែរ។ ការពិនិត្យទាំងនេះអាចត្រូវ បានធ្វើឡើងពីចម្ងាយដោយប្រើកម្មវិធីឌីជីថល ឬវិធីដែលអាចផ្ទៀងផ្ទាត់ផ្សេងទៀត ឬដោយផ្ទាល់បន្ទាប់ពី បុគ្គលមកដល់។ សាលារៀនត្រូវតែអនុវត្តតាមការណែនាំរបស់ DPH ស្តីពី ការត្រួតពិនិត្យរោគសញ្ញានិងការប៉ះពាល់របស់ សិស្ស ដើម្បីកំណត់ពីផ្លូវនៃការសម្រេចចិត្តសម្រាប់កុមារដែលមានរោគសញ្ញា និងអ្នកប៉ះពាល់កុមារដែល អាចបានឆ្លងជំងឺ។ ភ្ញៀវដែលជាមនុស្សធំ និងបុគ្គលិកដែលមានរោគសញ្ញាជំងឺ COVID-19 ឬដែលពិនិត្យឃើញថាវិជ្ជមាន ដូចបានពិពណ៌នានៅក្នុងការណែនាំអំពីការត្រួតពិនិត្យការចូលរបស់ DPH មិនអាចចូលក្នុងទីកន្លែងបានទេ។ សិស្សដែលពិនិត្យឃើញថាវិជ្ជមានសម្រាប់រោគសញ្ញាដែលដូចគ្នាជាមួយជំងឺ COVID-19 ដែលអាចកើតឡើង គួរទទួលបានម៉ាស់ពេទ្យ និងនាំទៅកន្លែងដាក់ឲ្យនៅដាច់ដោយឡែកដែលបានជ្រើសរើសជាមុន ដែលពួកគេអាចនៅទីនោះ ខណៈដែលសេចក្តីសម្រេចកំពុងត្រូវបានធ្វើឡើងទាក់ទងនឹងការមិនរាប់បញ្ចូល ហើយការរៀបចំត្រូវបានធ្វើឡើងសម្រាប់ឲ្យពួកគេត្រឡប់ទៅផ្ទះ នៅពេលមានការចង្អុលបង្ហាញ។ បុគ្គលិកសេវាវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ កំពុងឆ្លើយតបនឹងតម្រូវការវេជ្ជសាស្ត្របន្ទាន់ ត្រូវបានលើកលែងពីការត្រួតពិនិត្យ។

☑ *ចាំបាច់៖* ភ្ញៀវមកកាន់ទីកន្លែងសាលារៀនត្រូវបានហាមឃាត់ លើកលែងអ្នកដែលកំពុងផ្តល់សេវា និង/ឬការគាំទ្រដែលចាំបាច់សម្រាប់បេសកកម្ម និង/ឬប្រតិបត្តិការរបស់សាលា។ ការត្រួតពិនិត្យការចូល និងក្រណាត់បាំងមុខ គឺចាំបាច់សម្រាប់ភ្ញៀវសំខាន់ៗ។ មន្ត្រីអនុវត្តច្បាប់ (នគរបាល និងប៉ូលិស) បុគ្គលិកពន្លត់អគ្គីភ័យ វេជ្ជសាស្ត្រ សង្គ្រោះបន្ទាន់ ឬបុគ្គលិករដ្ឋាភិបាលដែលកំពុងឆ្លើយតប កំពុងធ្វើការ ឬកំពុងត្រួតពិនិត្យបរិក្ខារអាចចូលទៅកាន់ទីកន្លែងបាន។

☑ *ចាំបាច់៖* សាលារៀនត្រូវតែបញ្ឈប់សកម្មភាពជាក្រុមដោយផ្ទាល់ដែលមិនចាំបាច់ទាំងអស់នៅទីកន្លែងក្នុងអំឡុងការផ្ទុះជំងឺ។

**សម្រាប់ធនធានបន្ថែមអំពីជំងឺ COVID-19 សម្រាប់សាលារៀន K-12 សូមចូលទៅកាន់៖**
**http://publichealth.lacounty.gov/media/Coronavirus/reopening-la.htm#k12 និង**
**http://ph.lacounty.gov/acd/ncorona2019/EducationToolkit/TK12**